00184967 C22/I/24

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

អង្គបុរេជំនុំជម្រះ

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នេយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 30 / 04 / 2008
ម៉ោង (Time/Heure): 15 h 40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

កាលបរិច្ឆេទ: ៣០ មេសា ២០០៨

# សេចក្ដីសម្រេចលើសំណើសុំឲ្យមានសវនាការដាច់ដោយឡែករវាងសវនាការអំពីយុត្តាធិការ និងសវនាការអំពីការឃុំខ្លួនបណ្ដោះអាសន្នរបស់ អៀង សារី

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 30 / 04 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

**ជនត្រូវចោទ**
អៀង សារី

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke STUDZINSKY

**សហមេធាវីការពារក្ដី**
អាង ឧត្ដម
Michael G.KARNAVAS

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

១- **អង្គបុរេជំនុំជម្រះ** ទទួលបាន "សំណើសុំឲ្យមានសវនាការដាច់ដោយឡែករវាងសវនាការអំពីយុត្តាធិការ និងសវនាការអំពីការឃុំខ្លួនបណ្តោះអាសន្នរបស់ **អៀង សារី** " ដែលបានដាក់ចូលមកនៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៨ *("សំណើ")* ។

២- នៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានតបទៅនឹង *សំណើ* នេះ។

៣- មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីពុំបានដាក់សារណាតបណាមួយឡើយ។

៤- នៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៨ ជនត្រូវចោទបានដាក់សារណាតបទៅនឹងសេចក្តីសន្និដ្ឋានតបរបស់សហ-ព្រះរាជអាជ្ញា។

៥- សហមេធាវីការពារក្តីស្នើសុំឲ្យអង្គបុរេជំនុំជម្រះ បើកសវនាការ និងប្រកាសសាលដីកាអំពីបញ្ហាយុត្តាធិការដាច់ដោយឡែកពីសវនាការ និងប្រកាសសាលដីកាអំពីការឃុំខ្លួនបណ្តោះអាសន្ន។

៦- នៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីសំណើសុំឲ្យផ្អាកពិចារណា **ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ** ២០០៨ អង្គបុរេជំនុំជម្រះ បានបដិសេធសំណើសុំផ្អាកការពិចារណាលើបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន។មូលហេតុស្នើសុំឲ្យធ្វើដាច់ដោយឡែកពីគ្នាដែលសហមេធាវីការពារក្តីលើកឡើងមានកម្រិតចំពោះ "មូលហេតុក្នុងការកំណត់ពេលវេលាជាក់ស្តែង" បន្ទាប់ពីសេចក្តីសម្រេចនេះ។ សហមេធាវីការពារក្តីពុំបានធ្វើការពន្យល់ថាតើហេតុអ្វីបានជាមូលហេតុក្នុងការកំណត់ពេលវេលាជាក់ស្តែង តម្រូវឲ្យមានការធ្វើដាច់ដោយឡែកពីគ្នាបែបនេះទេ។

៧- អង្គបុរេជំនុំជម្រះពុំបានមើលឃើញមូលហេតុក្នុងការកំណត់ពេលវេលាជាក់ស្តែងណាមួយ ដែលនាំឲ្យមានការធ្វើដាច់ដោយឡែកពីគ្នាបែបនេះឡើយ។ ដូចបានពិចារណាក្នុងសេចក្តីសម្រេចចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៨ កម្មវត្ថុនៃយុត្តាធិការត្រូវបានបញ្ចូលទៅក្នុងរឿងបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះនឹងដោះស្រាយបញ្ហាទាំងអស់នៅពេលជាមួយគ្នានៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេច:**

*បដិសេធសំណើសុំបើកសវនាការ និងប្រកាសសាលដីកាដាច់ដោយឡែកពីគ្នា របស់ជនត្រូវចោទ។* ៧ី

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

**ប្រាក់ គឹមសាន**